# ធនាគារជាតិ នៃ កម្ពុជា

## ព្រឹត្តិបត្រប្រចាំត្រីមាស







## លេខ ២៣

## ត្រីមាសទី១ ឆ្នាំ២០០៨

ចេញផ្សាយតាមប្រកាសលេខ ធ១.០២.១២៦ ប្រ.ក ចុះថ្ងៃទី០២ ខែមេសា ឆ្នាំ២០០២

# អារម្ភកថា



**ឯកឧត្តម ជា ចាន់តូ**
**ទេសាភិបាលធនាគារជាតិនៃកម្ពុជា**

**ប្រិយមិត្តអ្នកអាន ជាទីមេត្រី !**

កំណើនសេដ្ឋកិច្ចដ៏មានចីរភាពអាចជួយដល់ការកាត់បន្ថយភាពក្រីក្រយ៉ាងមានប្រសិទ្ធភាព ហើយបទពិសោធន៍បណ្តាប្រទេសដែលទទួលបានកំណើនសេដ្ឋកិច្ចជាបន្តបន្ទាប់ក្នុងរយៈពេលវែង បានបង្ហាញឱ្យឃើញពីការថយចុះយ៉ាងឆាប់រហ័សនៃកម្រិតភាពក្រីក្រ ។ ប៉ុន្តែ វិបត្តិសេដ្ឋកិច្ចអាចគំរាមកំហែងដល់ការអភិវឌ្ឍ បើទោះជាប្រទេសរងវិបត្តិទាំងឡាយអាចងើបឡើងវិញយ៉ាងឆាប់រហ័សក៏ដោយ ក៏គេមិនអាចវិលត្រឡប់ទៅដល់កម្រិតអភិវឌ្ឍន៍ដែលធ្លាប់ទទួលបានមុនពេលកើតមានវិបត្តិបានភ្លាមៗទេ ដូច្នេះ ទោះជាយ៉ាងណាក៏នាំឱ្យមានការយឺតយ៉ាវដល់ដំណើរការអភិវឌ្ឍសេដ្ឋកិច្ចដែរ ។ ដោយសារតែវិបត្តិសេដ្ឋកិច្ចអាចមានផលវិបាកដល់ការអភិវឌ្ឍយូរអង្វែង ធនាគារជាតិនៃកម្ពុជាក្នុងនាមជាអាជ្ញាធរបញ្ញត្តកម្មបានរួមចំណែកបង្កើនការយល់ដឹងអំពីមូលហេតុនៃវិបត្តិ និងការកសាងគោលនយោបាយដើម្បីយល់ដឹងពីលទ្ធភាពនៃការកើតឡើងនិងបញ្ចៀស ឬកាត់បន្ថយការខូចខាតដោយសារវិបត្តិរូបិយវត្ថុ ។

ដប់ឆ្នាំមុននេះ បណ្តាសេដ្ឋកិច្ចប្រទេសអាស៊ីដែលកំពុងងើបឡើង បានរងគ្រោះដោយវិបត្តិដែលបានចាប់ផ្តើមពីប្រទេសថៃ ហើយរាលដាលដល់កូរ៉េ ឥណ្ឌូណេស៊ី និងម៉ាឡេស៊ី ។ វាជាការសបញ្ជាក់មួយថា តើភាពផុយស្រួយនៃលំហូរមូលនិធិឯកជនអាចផ្តល់ផលវិបាកធ្ងន់ធ្ងរប៉ុណ្ណាដល់សេដ្ឋកិច្ចរបស់បណ្តាប្រទេសដែលមាននយោបាយនិងស្ថាប័នទន់ខ្សោយសម្រាប់ទប់ទល់នឹងលំហូរមូលនិធិ ។ វិបត្តិបានផ្ទុះឡើងក្រោយពេលដែលលំហូរនៃមូលនិធិភាគធំជាប្រភេទវិនិយោគរយៈពេលខ្លី បានបង្កឱ្យមានទំនាស់ធំពីរគឺ ឥណទានរយៈពេលខ្លីនៃការផ្តល់ទុនជាមួយតម្រូវការវែងនៃការប្រើប្រាស់ទុន និងទំនាស់អត្រាប្តូរប្រាក់ ហើយជាលទ្ធផល គឺការហូរមូលនិធិចេញទៅវិញយ៉ាងគំហុក ដែលធនាគារកណ្តាលនៃប្រទេសរងគ្រោះពុំអាចទ្រាំទ្របាន ព្រោះរូបិយវត្ថុបានធ្លាក់ថ្លៃយ៉ាងខ្លាំងនិងឆាប់រហ័ស ហើយប្រព័ន្ធធនាគារចុះខ្សោយរកកលនឹងធនក្ស័យ ។

រាជរដ្ឋាភិបាលកំណត់ទិសដៅអភិវឌ្ឍន៍ទីផ្សារហិរញ្ញវត្ថុនៅកម្ពុជាឱ្យឈានដល់ការបង្កើតទីផ្សារហ៊ុននៅឆ្នាំ២០០៩ ដោយបានចាប់ផ្តើមរៀបចំមូលដ្ឋានគតិយុត្តក្នុងរយៈពេលប៉ុន្មានឆ្នាំកន្លងមក ដូចជា ការកសាងច្បាប់ និងបទបញ្ញត្តិ ដែលពាក់ព័ន្ធនឹងការជួញដូរមូលប័ត្រ ។ ទីផ្សារហិរញ្ញវត្ថុរឹងមាំ និងមានទំនុកចិត្តពីសាធារណជនទាំងក្នុង និងក្រៅប្រទេសនឹងនាំទៅដល់វត្តមាននៃលំហូរទុនយ៉ាងខ្លាំងក្លា ហើយការប្រតិបត្តិ និងការគ្រប់គ្រងត្រូវទាមទារទេពកោសល្យ បច្ចេកទេស សមត្ថភាព ព្រមទាំងគោលនយោបាយឆ្លើយតបទៅនឹងហានិភ័យ ដើម្បីទទួលបានប្រសិទ្ធភាពបង្កឱ្យមានការអភិវឌ្ឍកាន់តែឆាប់រហ័ស ។ ទីផ្សារហ៊ុនប្រៀបបាននឹងដំរីសា ដែលអាចជួយជាកម្លាំងខ្លាំងក្លាក្នុងការអភិវឌ្ឍ ប៉ុន្តែបើបាត់ម្ចាស់ការរៀបចំគោលនយោបាយ និងរចនាសម្ព័ន្ធស្ថាប័ន ព្រមទាំងការគ្រប់គ្រងមិនបានរឹងមាំល្អទេ ក៏ប្រៀបបានទៅនឹងដំរីចុះប្រេងបានដែរ ។

ធនាគារជាតិនៃកម្ពុជាជឿជាក់ថា ការចូលរួមរបស់វិស័យឯកជន គឺជាកម្លាំងស្នូលនៅក្នុងដំណើរការនេះ ។

សូមជូនពរ សិរីសួស្តី សុភមង្គល វិបុលសុខ មហាប្រសើរ ក្នុងឱកាសចូលឆ្នាំថ្មី ឆ្នាំសកល ២០០៨ ។

**សូមអរគុណ !**

# មាតិកា

ទំព័រ


- អនុក្រឹត្យស្តីពី ការចេញផ្សាយក្រដាសប្រាក់ ប្រភេទ ២០០០ រៀល គំរូថ្មី ១
- ប្រកាសស្តីពី លក្ខណៈសំគាល់នៃក្រដាសប្រាក់ ប្រភេទ ២០០០ រៀល គំរូថ្មី ២
- ប័ណ្ណប្រកាសអំពីក្រដាសប្រាក់គំរូថ្មី ប្រភេទ ២០០០ រៀល ៤
- គោលការណ៍អភិបាលកិច្ចល្អ ៦
- ប្រកាសស្តីពី ការផ្តល់អាជ្ញាប័ណ្ណទទួលប្រាក់បញ្ញើពីសាធារណជនរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ៣៥
- ប្រកាសស្តីពី ការប្រើប្រាស់ភាសា ឯកតារូបិយវត្ថុ និងអត្រាប្តូរប្រាក់សម្រាប់ចុះកិច្ចបញ្ជិកាគណនេយ្យ និងរាយការណ៍ ៤២
- ប្រកាសស្តីពី ការដាក់ឱ្យអនុវត្តគោលនយោបាយត្រួតពិនិត្យផ្ទៃក្នុងរបស់ធនាគារជាតិនៃកម្ពុជា ៤៦
- ប្រកាសស្តីពី ក្រមសីលធម៌សម្រាប់មន្ត្រីបុគ្គលិកអគ្គាធិការដ្ឋាន ធនាគារជាតិនៃកម្ពុជា ៥៧
- តារាងអត្រាប្តូរប្រាក់ប្រចាំខែ ក្នុងត្រីមាសទី៤ ឆ្នាំ២០០៧ ៦៨
- តារាងអត្រាការប្រាក់លើការឱ្យខ្ចីចងការ (រៀល និងរូបិយប័ណ្ណបរទេស) ប្រចាំខែធ្នូ ឆ្នាំ២០០៧ ៦៩
- តារាងអត្រាការប្រាក់លើប្រាក់បញ្ញើ (រៀល និងរូបិយប័ណ្ណបរទេស) ប្រចាំខែធ្នូ ឆ្នាំ២០០៧ ៧០
- បញ្ជីឈ្មោះគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ប្រចាំខែធ្នូ ឆ្នាំ២០០៧ ៧១
- ប្រព័ន្ធធនាគារនៅកម្ពុជា ប្រចាំខែធ្នូ ឆ្នាំ២០០៧ ៩១